# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ សៀមប៉ាង ខេត្តស្ទឹងត្រែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ [illegible]

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និង សត្វព្រៃសៀមប៉ាង ខេត្តស្ទឹងត្រែង ហៅកាត់ថាព្រៃការពារសៀមប៉ាង ដែលមានផ្ទៃក្រឡាទំហំ៦៦ ៩៣២ (ប្រាំមួយម៉ឺនប្រាំមួយពាន់ប្រាំបួនរយសាមសិបពីរ)ហិកតា ស្ថិតនៅក្នុងស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ការពារ អភិរក្ស និងស្តារឡើងវិញនូវធនធានសេនេទិច រុក្ខជាតិ សត្វព្រៃគ្រប់ប្រភេទ ជាពិសេសប្រភេទ ដែលកំពុងរងគ្រោះថ្នាក់ជាសាកល
- រក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិនិងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីដែលខូចខាត សម្រាប់ផ្តល់ជាទីជម្រកស្នាក់ អាស្រ័យ សុខសាន្តនិងការបន្តពូជរបស់ជីវៈចម្រុះគ្រប់ប្រភេទ
- ការពារប្រភពចំណីនិងថែរក្សាប្រភពទឹកឱ្យមានប្រក្រតីភាពសម្រាប់ជីវៈចម្រុះដើម្បីធានាឱ្យមាននិរន្តរភាព តំបន់ អេកូឡូស៊ី សេដ្ឋកិច្ចសង្គម និងបរិស្ថាន
- ការពារអភិរក្សសត្វត្រយងនិងសត្វព្រៃផ្សេងទៀត ពិសេសប្រភេទជិតផុតពូជ ប្រភេទដែលកំពុងទទួលរង គ្រោះថ្នាក់ និងទីជម្រកសុខសាន្តរបស់វា
- ទប់ស្កាត់និងលុបបំបាត់នូវរាល់សកម្មភាពកាប់រាន ដុត ឈូសឆាយ និងប្រែក្លាយធម្មជាតិព្រៃឈើជាដី សម្រាប់អភិវឌ្ឍដំណាំកសិកម្មឬរុក្ខជាតិប្រភេទផ្សេងក្រៅពីព្រៃឈើ
- ការពារបរិមាណស្តុកកាបូនដែលស្ថិតនៅក្នុងតំបន់ព្រៃការពារ ដើម្បីរួមចំណែកដល់ដំណើរការកាត់បន្ថយ ការសាយភាយឧស្ម័នកាបូនិចទៅក្នុងស្រទាប់បរិយាកាសនិងឈានទៅដល់ការលក់ឥណទានកាបូនព្រៃឈើ
- ទ្រទ្រង់សកម្មភាពផ្សេងៗរួមមាន ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស ការអប់រំផ្សព្វផ្សាយ បណ្តុះបណ្តាល អភិវឌ្ឍសហគមន៍ ការអង្កេតតាមដានពីភាពប្រែប្រួលបរិស្ថានដែលទាក់ទងនឹង ការអភិវឌ្ឍប្រកបដោយនិរន្តរភាព
- ការពារការហូរច្រោះដី ជីជាតិដី ទីជម្រាល សម្បត្តិវប្បធម៌ធម្មជាតិ អភិរក្សជីវចម្រុះ និរន្តរភាព ប្រភពទឹក និងគុណភាពទឹក ។

- រក្សាការប្រើប្រាស់ធនធានធម្មជាតិដោយសហគមន៍មូលដ្ឋាន ដើម្បីលើកស្ទួយកម្រិតជីវភាពប្រជាជនរស់នៅក្នុងឬក្បែរតំបន់និងរួមចំណែកក្នុងកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល
- រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាព តាមរយៈការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានព្រៃឈើ ដោយសហគមន៍មូលដ្ឋាន អភិវឌ្ឍគោលដៅអេកូទេសចរណ៍ និងសកម្មភាពប្រើប្រាស់ផ្សេងទៀតដែលមានផលប៉ះពាល់ទាបដល់ធនធានសេនេទិច ព្រៃឈើ និងសត្វព្រៃ។

## ជំពូកទី២
## ការកំណត់តំបន់ព្រៃការពារសៀមប៉ាង

**មាត្រា៣ .-**

តំបន់ព្រៃការពារសៀមប៉ាងមានព្រំប្រទល់ជាខ្សែព្រំបិទជិតកំណត់ដោយបណ្តាចំណុចគោលចេញពីចំណុចA ចំណុចB រហូតដល់ចំណុចP និងស្របតាមបណ្តោយខ្សែបន្ទាត់ព្រំដែនកម្ពុជា ឡាវ ដែលមាននិយាមកា៖

A(673094, 1602988) B(668737, 1602301) C(666051, 1607579) D(657731, 1597515) E(653383, 1589520) F(654415, 1580440) G(656002, 1575249) H(652531, 1570186) I(648697, 1570750) J(647967, 1576089) K(639743, 1581196) L(633984, 1581755) M(628857, 1580205) N(622533, 1581670) O(619487, 1585258) និងP(617260, 1587395)

ដូចមានផែនទីបឋមមាត្រដ្ឋាន១/២៥០ ០០០ ភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។ ចំណុចនិយាមកាទាំងនេះ ប្រើប្រាស់សម្រាប់កំណត់តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ សៀមប៉ាង ខេត្តស្ទឹងត្រែង ប៉ុណ្ណោះ ពុំមានឥទ្ធិពលផ្លូវច្បាប់ទៅលើការកំណត់ព្រំដែនរវាងប្រទេសនិងប្រទេសឡើយ។

**មាត្រា៤ .-**

ផ្ទៃក្រឡានៃតំបន់ព្រៃការពារសៀមប៉ាងដូចមានចែងក្នុងមាត្រា៣ខាងលើនេះ អាចធ្វើការកែប្រែបានតាមការចាំបាច់ ដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រជាមូលដ្ឋាន និងស្ថានភាពជាក់ស្តែងនាពេលអនាគត។ ការកែប្រែនេះត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៣
## ការគ្រប់គ្រង

**មាត្រា៥ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសមត្ថកិច្ចរៀបចំនិងគ្រប់គ្រងព្រៃការពារសៀមប៉ាងដោយសហការជាមួយក្រសួងពាក់ព័ន្ធនិងរដ្ឋបាលដែនដី ដើម្បីធានានូវការអភិវឌ្ឍធនធានធម្មជាតិប្រកបដោយនិរន្តរភាពសម្រាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់នោះ។

ដំណើរការនៃការរៀបចំគ្រប់គ្រងតំបន់និងអភិរក្សព្រៃការពារសៀមប៉ាង ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ផែនទីបង់ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៧៦៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពី

## ការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ "សៀមប៉ាង" ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង






**សញ្ញាសំគាល់**

- ● ទីតាំងភូមិ
- ▲ ទីតាំងឃុំ
- ⊙ ចំណុចគោល
- ផ្លូវទឹក
- ផ្លូវ
- ព្រំប្រទល់ប្រទេស
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់ព្រៃការពារ
- សម្បទានដីសេដ្ឋកិច្ច
- តំបន់ការពារ

**គម្របព្រៃឈើឆ្នាំ ២០១០**

- ព្រៃស្រោង ១៩ ៤០៥ ហ.ត
- ព្រៃពាក់កណ្តាលស្រោង ២៦ ៧២០ ហ.ត
- ព្រៃល្បោះ ១៥ ២៧៥ ហ.ត
- ព្រៃផ្សេង១ ៤២៥ ហ.ត
- ព្រៃគុម្ពោតស្ងួត ២៨២ ហ.ត
- ដីគ្មានគំរបព្រៃ ៤ ៧២៥ ហ.ត

**ផ្ទៃដីសរុប ៦៦ ៩៣២ ហិកតា**

បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អ៊ឹម ឈុនលឹម

បណ្ឌិត អ៊ុក រ៉ាប៊ុន